**មេរៀនទី ១**

# អាតូម និងទស្សនៈសំខាន់ៗ

រាងកាយយើង កៅអី សត្វកាំប្រម៉ា និងសៀវភៅនេះ ទាំងអស់នេះសុទ្ធតែមានអ្វីជារួមនឹងគ្នា។ រាងកាយយើងបង្កឡើងដោយអាតូម ដូចគ្នាទៅនឹងអ្វីផ្សេងៗទៀតនៅលើផែនដីដែរ។ អាតូមមានទំហំតូចណាស់ ទោះបីជាយើងធ្វើការពង្រីកសក់មួយសរសៃរបស់យើងឱ្យធំប៉ុនណាក៏ដោយ ក៏យើងមិនអាចមើលឃើញអាតូមមួយៗដែរ។ តាមពិតមានអាតូមរាប់ពាន់លាន នៅក្នុងចំណុចដ៏តូចមួយនេះ (.)។ គេគ្រាន់តែសាកល្បងនឹកស្មានបែបនោះ និងបន្ទាប់មកសាកល្បងស្មាននូវអាតូមរាប់ពាន់លានមិនអាចរាប់បាន ដែលបង្កជារូបរាងកាយអ្នកឡើង។

គំនិតស្តីពីអាតូមត្រូវបានគេទទួលស្គាល់អស់រយៈពេលជាងពីររយឆ្នាំមកហើយ។ ដោយសារវាតូចពេកធ្វើឱ្យគេពិបាកនឹងបង្ហាញពីវត្តមានរបស់វាណាស់។ ប៉ុន្តែសព្វថ្ងៃយើងអាចមើលវាឃើញដោយប្រើមីក្រូទស្សន៍អេឡិចត្រូនិចដែលមានអនុភាពខ្ពស់។

គីមីគឺជាការសិក្សាអំពីអាតូមទាំងឡាយ ថាតើវាមានលក្ខណៈសំគាល់យ៉ាងដូចម្តេច វាចងភ្ជាប់គ្នាយ៉ាងដូចម្តេច ហើយយើងអាចប្រើវាបានយ៉ាងដូចម្តេច។ អាតូមទាំងឡាយគឺជាគំនិតដ៏អស្ចារ្យរបស់គីមីវិទូ ហើយយើងនឹងស្វែងយល់វាឱ្យច្រើនជាងនេះទៀតនៅក្នុងមេរៀននេះ។

## ១ អាតូម ធាតុគីមី និងសមាសធាតុ

### ១.១ អាតូម



*ស័ង្កសីផ្សំពីភាគល្អិតតូចៗបំផុត ដែលហៅថា អាតូមស័ង្កសី។*



*ទង់ដែងផ្សំពីអាតូមទង់ដែង ដែលខុសពីអាតូមស័ង្កសី។*



*មាសផ្សំពី អាតូមមាស ដែល ខុសពីអាតូមស័ង្កសី និងទង់ដែង។*

អាតូមជាភាគល្អិតដ៏តូចបំផុត។ វាស្ទើរតែជាលំហទទេមួយ។ អាតូមនីមួយៗមាន**ណ្វៃយ៉ូ** មួយនិងពពកនៃភាគល្អិតដែលហៅថា**អេឡិចត្រុង**ធ្វើចលនាជុំវិញណ្វៃយ៉ូ។ រូបខាងស្តាំបង្ហាញនូវអ្វីដែលអាតូមសូដ្យូមមួយអាចមើលឃើញដោយការពង្រីកប្រហែលជា 100 លានដង ។



# ១.២ ធាតុគីមី

ធាតុគីមីមួយផ្សំឡើងពីអាតូមតែមួយប្រភេទប៉ុណ្ណោះ។ *ឧទាហរណ៍* សូដ្យូមផ្សំឡើងពីអាតូមសូដ្យូមតែមួយប្រភេទ ដូច្នេះវាជា**ធាតុគីមី**មួយ។

អ្នកវិទ្យាសាស្ត្រនៅតែរកឃើញនូវធាតុគីមីថ្មីនានា។ រហូតមកដល់ពេលនេះមានធាតុគីមីចំនួន 109 ហើយត្រូវបានគេស្គាល់ និងកំណត់ឈ្មោះជាផ្លូវការ។ ក្នុងចំណោមធាតុគីមីទាំងអស់ ធាតុគីមីចំនួន 90 ត្រូវបានរកឃើញថាមាននៅក្នុងស្រទាប់ផែនដី និងបរិយាកាស ហើយធាតុនៅសល់ផ្សេងទៀតត្រូវបានបង្កើតឡើងនៅក្នុងទីពិសោធ។ ធាតុគីមីជាច្រើនក្នុងចំណោមធាតុគីមីសិប្បនិម្មិតទាំងអស់មានអាយុកាលបានត្រឹមតែប៉ុន្មានវិនាទីប៉ុណ្ណោះ បន្ទាប់មកក៏បំបែកទៅជាធាតុគីមីផ្សេង ទៀត។

## ១.២.១ និមិត្តសញ្ញានៃធាតុគីមី

ដើម្បីឱ្យមានភាពងាយស្រួលសំគាល់ ធាតុគីមីនីមួយៗមាននិមិត្តសញ្ញាមួយ។ និមិត្តសញ្ញាទាំងនេះ ជាទូទៅត្រូវបានកំណត់យកតាមឈ្មោះអង់គ្លេស ឬឡាតាំង ដូចជានិមិត្តសញ្ញាកាបូន C មកពីឈ្មោះអង់គ្លេស Carbon។ និមិត្តសញ្ញាប៉ូតាស្យូម K មកពីឈ្មោះឡាតាំង Kalium ។ ឈ្មោះធាតុគីមីមួយចំនួនត្រូវបានកំណត់តាមឈ្មោះអ្នកដែលរកឃើញវា។

## ១.២.២ តារាងខួបនៃធាតុគីមី

តារាងនៅខាងក្រោមទំព័រនេះជាតារាងខួបដែលមានសារៈសំខាន់ និងមានប្រយោជន៍បំផុតក្នុងផ្នែកគីមី។ វាប្រដូចទៅនឹងផែនទីមួយ ពីព្រោះធាតុគីមីទាំងអស់សុទ្ធតែមានទីតាំងកំណត់នៅក្នុងតារាងនេះ។

**តារាងខួបនៃធាតុគីមី**



- វាកំណត់ឈ្មោះ និងនិមិត្តសញ្ញាធាតុគីមីនានា ។
- ជួរឈរ ឬ**ក្រុម**ដែលមានបង់លេខជាអំបូរនៃធាតុដែលមានលក្ខណៈស្រដៀងគ្នា ។ ដូចនេះបើអ្នកស្គាល់លក្ខណៈសំគាល់នៃធាតុមួយក្នុងក្រុមណាមួយ អ្នកអាចព្យាករណ៍បានពីលក្ខណៈសំគាល់នៃធាតុផ្សេងទៀតដែលនៅក្នុងក្រុមជាមួយគ្នា ។
- ជួរដេក ហៅថា**ខួប** ។
- បន្ទាត់កាច់ជិតច្បាស់ញែកលោហៈពីអលោហៈ ដោយអលោហៈនៅខាងស្តាំ ហើយក្រៅពីនោះភាគច្រើនជាលោហៈនៅផ្នែកខាងឆ្វេង ។

## ១.៣ សមាសធាតុ

ធាតុគីមីទាំងឡាយអាចផ្សំគ្នាបង្កើតបានជា **សមាសធាតុ** ។ **សមាសធាតុមួយមានអាតូម នៃធាតុគីមីខុសៗគ្នាជាច្រើនផ្សំគ្នា** ។ យើងនិយាយថាអាតូមទាំងឡាយត្រូវបាន**ផ្សំដោយវិធីគីមី** បង្កើតបានជាសមាសធាតុរាប់លាន ។ តារាងខាងក្រោម នេះបង្ហាញពីសមាសធាតុងាយៗចំនួនបី ÷

| ឈ្មោះសមាសធាតុ | ធាតុគីមីដែលផ្សំ | របៀបចងសម្ព័ន្ធរបស់អាតូម |
|---|---|---|
| ទឹក | អ៊ីដ្រូសែន និងអុកស៊ីសែន |   |
| កាបូនឌីអុកស៊ីត | កាបូន និងអុកស៊ីសែន |   |
| អេតាណុល | កាបូន អ៊ីដ្រូសែន និងអុកស៊ីសែន |   |

## ១.៤ និមិត្តសញ្ញាសមាសធាតុ

និមិត្តសញ្ញាសមាសធាតុមានឈ្មោះថា**រូបមន្ត** ។ វាត្រូវបានរៀបចំឡើងពីនិមិត្តសញ្ញានៃធាតុគីមីដែលផ្សំវា ។ ដូចនេះ រូបមន្តរបស់ទឹកគឺ $H_2O$ ។

### សំណួរ

1. តើអ្វីទៅជាអាតូម ?
2. តើផ្នែកដែលនៅចំមណ្ឌលនៃអាតូមមានឈ្មោះអ្វី ?
3. ចូរពន្យល់ថាតើអ្វីទៅជាធាតុគីមី ។
4. ចូរឱ្យឈ្មោះធាតុគីមីដែលមាននិមិត្តសញ្ញាដូចតទៅ ÷

   ក- Ca   ខ- Mg   គ- N   ឃ- Ne ។
5. ដោយប្រើតារាងខួបជាជំនួយ ចូរកំណត់ឈ្មោះលោហៈបីដែលអ្នកគិតថាមានលក្ខណៈសំគាល់ស្រដៀងគ្នា ។

6. តើអ្វីទៅជាសមាសធាតុ?
7. ដោយប្រើតារាងខាងលើ ចូរសរសេររូបមន្តរបស់

ក- កាបូនឌីអុកស៊ីត ខ- អេតាណុល ។

# ២ ការសិក្សាបន្ថែមអំពីអាតូម

## ២.១ ប្រូតុង ណឺត្រុង និងអេឡិចត្រុង

អាតូមមាន**ណ្វៃយ៉ូ** និងពពក**អេឡិចត្រុង**ដែលធ្វើចលនាជុំវិញណ្វៃយ៉ូ ។ ណ្វៃយ៉ូផ្ទាល់មានភាគល្អិតពីរប្រភេទទៀតគឺ **ប្រូតុង** និង**ណឺត្រុង**។ ភាគល្អិតដែលមាននៅក្នុងអាតូមស្រាលខ្លាំងណាស់ ម៉ាសរបស់វាត្រូវបានគិតជា**ខ្នាតម៉ាសអាតូម** ជាជាងគិតជា ក្រាម ។ ប្រូតុង និងអេឡិចត្រុងមាន**បន្ទុកអគ្គិសនី**។

| ភាគល្អិតក្នុងអាតូម | ម៉ាស | បន្ទុក |
|---|---|---|
| ប្រូតុង • | 1ខ្នាតម៉ាសអាតូម | បន្ទុកវិជ្ជមាន (+1) |
| ណឺត្រុង • | 1ខ្នាតម៉ាសអាតូម | គ្មានបន្ទុក |
| អេឡិចត្រុង × | អាចចោលបាន | បន្ទុកអវិជ្ជមាន (-1) |

*សំគាល់÷* ប្រសិនបើគេធ្វើការពង្រីកអាតូមឱ្យធំប៉ុនទីលានបាល់ទាត់ នោះណ្វៃយ៉ូរបស់វា នឹងមានទំហំប៉ុនគ្រាប់សណ្តែកមួយប៉ុណ្ណោះ ។

## ២.២ ការតម្រៀបរបស់ភាគល្អិត

អាតូមសូដ្យូមមាន11អេឡិចត្រុង 11ប្រូតុង និង12ណឺត្រុង និងតម្រៀបដូចរូបខាងក្រោមនេះ ។




## ២.៣ លេខលំដាប់ ឬលេខអាតូម

អាតូមសូដ្យូមមាន11ប្រូតុង។ ប្រការនេះត្រូវបានគេប្រើដើម្បីកំណត់អត្តសញ្ញាណរបស់វាពីព្រោះមានតែអាតូមសូដ្យូមទេដែលមាន11ប្រូតុង។ អាតូមប្រភេទផ្សេងទៀតមានចំនួនប្រូតុងខុសៗគ្នា។ គេអាចកំណត់អត្តសញ្ញាណរបស់

អាតូមមួយ ដោយចំនួនប្រូតុងរបស់វា។ ចំនួនប្រូតុងទាំងអស់របស់អាតូមត្រូវបានគេឱ្យឈ្មោះថា **លេខលំដាប់** ឬ**លេខអាតូម**។ លេខលំដាប់ ឬលេខអាតូមរបស់សូដ្យូមគឺ 11។

## ២.៤ ចំនួនអេឡិចត្រុង

អាតូមសូដ្យូមមាន 11អេឡិចត្រុង ដូច្នេះវាមានចំនួនប្រូតុងស្មើនឹងចំនួនអេឡិចត្រុង។ **គ្រប់ប្រភេទអាតូមទាំងអស់មានចំនួនប្រូតុង និងចំនួនអេឡិចត្រុងស្មើគ្នា**។ ហេតុនេះហើយបានជាធ្វើឱ្យអាតូមគ្មានបន្ទុក (ណឺតតាមន័យអគ្គិសនី)។ បន្ទុករបស់អេឡិចត្រុងត្រូវបានទូទាត់ដោយបន្ទុករបស់ប្រូតុង។

បន្ទុកនៅលើអាតូមសូដ្យូម

●●●● 11ប្រូតុង
●●●●
●●● ប្រូតុងនីមួយៗមានបន្ទុក +1
បន្ទុកសរុប +11

×××× 11អេឡិចត្រុង
×××× អេឡិចត្រុងនីមួយៗមានបន្ទុក-1
××× បន្ទុកសរុប-11

ផលបូកបន្ទុក (+11) + (-11)= 0
ដូចនេះ អាតូមគ្មានបន្ទុកសរុបទេ។

## ២.៥ ចំនួនម៉ាស

ម៉ាសរបស់អាតូមមួយកំណត់ដោយប្រូតុង និងណឺត្រុង ដោយអេឡិចត្រុងស្ទើរតែគ្មានម៉ាស។ ដូចនេះ ចំនួនប្រូតុង និងចំនួនណឺត្រុងសរុបនៅក្នុងអាតូមមួយត្រូវបានគេហៅថា**ចំនួនម៉ាស**។

**ចំនួនម៉ាស = ចំនួនប្រូតុង + ចំនួនណឺត្រុង**

ចំនួនម៉ាសសូដ្យូមគឺ 23 (11 + 12 = 23)

តាមតារាងខួប សូដ្យូមត្រូវសម្តែងជា $^{23}_{11}Na$ ។ នេះបង្ហាញថា អាតូមសូដ្យូមមានចំនួនម៉ាស 23 និងលេខលំដាប់ 11។ ដូច្នេះ អ្នកក៏ដឹងដែរថាវាមាន 12ណឺត្រុង (23 - 11 = 12)។

## ២.៦ អាតូមនៃធាតុគីមី20ដំបូង

នៅក្នុងតារាងខួប ធាតុគីមីត្រូវបានរៀបតាមលេខលំដាប់ ឬលេខអាតូមកើនឡើង។ ខាងក្រោមនេះគឺជាធាតុគីមី 20 ដំបូង ÷

| ធាតុគីមី | និមិត្តសញ្ញា | លេខលំដាប់ ឬលេខអាតូម (ចំនួនប្រូតុង) | ចំនួនអេឡិចត្រុង | ចំនួនណឺត្រុង | ចំនួនម៉ាស (ចំនួនប្រូតុង + ចំនួនណឺត្រុង) |
|---|---|---|---|---|---|
| អ៊ីដ្រូសែន | H | 1 | 1 | 0 | 1 |
| អេល្យូម | He | 2 | 2 | 2 | 4 |
| លីចូម | Li | 3 | 3 | 4 | 7 |
| បេរីល្យូម | Be | 4 | 4 | 5 | 9 |

| | | | | | |
|---|---|---|---|---|---|
| បរ | B | 5 | 5 | 6 | 11 |
| កាបូន | C | 6 | 6 | 6 | 12 |
| អាសូត | N | 7 | 7 | 7 | 14 |
| អុកស៊ីសែន | O | 8 | 8 | 8 | 16 |
| ភ្លុយអរ | F | 9 | 9 | 10 | 19 |
| នេអុង | Ne | 10 | 10 | 10 | 20 |
| សូដ្យូម | Na | 11 | 11 | 12 | 23 |
| ម៉ាញ៉េស្យូម | Mg | 12 | 12 | 12 | 24 |
| អាលុយមីញ៉ូម | Al | 13 | 13 | 14 | 27 |
| ស៊ីលីស្យូម | Si | 14 | 14 | 14 | 28 |
| ផូស្វរ | P | 15 | 15 | 16 | 31 |
| ស្ពាន់ធ័រ | S | 16 | 16 | 16 | 32 |
| ក្លរ | Cl | 17 | 17 | 18 | 35 |
| អាកុង | Ar | 18 | 18 | 22 | 40 |
| ប៉ូតាស្យូម | K | 19 | 19 | 20 | 39 |
| កាល់ស្យូម | Ca | 20 | 20 | 20 | 40 |

## សំណួរ

1. ចូរឱ្យឈ្មោះភាគល្អិតនានាដែលបង្កអាតូម ។
2. តើភាគល្អិតណាមួយដែលមាន ÷

   ក- បន្ទុកវិជ្ជមាន? ខ- គ្មានបន្ទុក? គ- ស្ទើរតែគ្មានម៉ាស?
3. អាតូមមួយមាន 9 ប្រូតុង ។ តើវាជាធាតុអ្វី?
4. ហេតុអ្វីបានជាអាតូមទាំងឡាយគ្មានបន្ទុក?
5. ដូចម្តេចដែលហៅថា ?

   ក- លេខលំដាប់ ឬលេខអាតូម ខ- ចំនួនម៉ាស
6. ចូរប្រាប់ឈ្មោះអាតូមខាងក្រោមនេះ ។ តើវាមានចំនួនប្រូតុង អេឡិចត្រុង និងណឺត្រុងប៉ុន្មាន ÷

   ${}^{12}_{6}C$ ${}^{16}_{8}O$ ${}^{24}_{12}Mg$ ${}^{27}_{13}Al$ ${}^{64}_{29}Cu$ ។

# ៣ អ៊ីសូតូប និងម៉ាសមធ្យម

*រំលឹក÷* តើគេកំណត់រកអត្តសញ្ញាណអាតូមណាមួយយ៉ាងដូចម្តេច?

មានតែអាតូមសូដ្យូមទេដែលមាន 11 ប្រូតុង ។ គេអាចសំគាល់អាតូមមួយបានដោយចំនួនប្រូតុងរបស់វា ។

## ៣.១ អ៊ីសូតូប

អាតូមអ៊ីដ្រូសែនខាងក្រោមនេះមានប្រូតុងតែមួយប៉ុណ្ណោះ ប៉ុន្តែអាតូមទាំងអស់នេះមិនដូចគ្នាទេដោយសារវាមានចំនួនណឺត្រុងខុសៗគ្នា ។

| | | |
|---|---|---|
|  |  |  |
| អាតូមអ៊ីដ្រូសែនភាគច្រើនគឺមានទម្រង់ $^{1}_{1}H$ ។ វាមាន 1 ប្រូតុង និង 1 អេឡិចត្រុង ប៉ុន្តែគ្មានណឺត្រុងទេ ។ | ប៉ុន្តែក៏មានទម្រង់ខ្លះបែបនេះដែរ ដោយវាមាន 1 ណឺត្រុង ។ វាមានឈ្មោះថា ដឺតេរ្យ៉ូម $^{2}_{1}H$ ។ | ហើយខ្លះទៀតក៏មានទម្រង់បែបនេះដែរ ដោយវាមាន 2 ណឺត្រុង និងមានឈ្មោះថា ទ្រីចូម $^{3}_{1}H$ ។ |

អាតូមទាំងបីនេះគេឱ្យឈ្មោះថា **អ៊ីសូតូប**អ៊ីដ្រូសែន ។ *អ៊ីសូតូបគឺអាតូមនៃធាតុគីមីប្រភេទដូចគ្នាតែមានចំនួនណឺត្រុងខុសគ្នា* ។

ធាតុគីមីភាគច្រើនមានអ៊ីសូតូប ។ កាល់ស្យូមមាន 6 អ៊ីសូតូប ម៉ាញ៉េស្យូមមាន 3 អ៊ីសូតូប ប្រាក់មាន 2 អ៊ីសូតូប ហើយកាបូនមាន 3 អ៊ីសូតូប តារាងខាងក្រោមបង្ហាញពីអ៊ីសូតូបរបស់កាបូន ។

| ឈ្មោះ | និមិត្តសញ្ញា | ចំនួនប្រូតុង | ចំនួនអេឡិចត្រុង | ចំនួនណឺត្រុង | ចំនួនម៉ាស |
|---|---|---|---|---|---|
| កាបូន-12 | $^{12}_{6}C$ | 6 | 6 | 6 | 12 |
| កាបូន-13 | $^{13}_{6}C$ | 6 | 6 | 7 | 13 |
| កាបូន-14 | $^{14}_{6}C$ | 6 | 6 | 8 | 14 |

អ៊ីសូតូបទាំងបីនេះកើតមាននៅក្នុងធម្មជាតិ ដូចជានៅក្នុងកាបូនឌីអុកស៊ីត ដែលមានក្នុងខ្យល់ ។ ប៉ុន្តែអាតូមកាបូន-13 មានតែ 1% ប៉ុណ្ណោះ ហើយអាតូមកាបូន-14 មានភាគរយតិចតួចបំផុត ។

## ៣.២ អ៊ីសូតូប និងលក្ខណៈវិទ្យុសកម្ម

កាបូន-14 ជា**ធាតុវិទ្យុសកម្ម** ។ វាគ្មានស្ថិរភាពទេ មិនយូរមិនឆាប់អាតូមនេះនឹងត្រូវបែក ឬបំលែងដោយមានបញ្ចេញកាំរស្មី ។ ធាតុគីមីជាច្រើនមានអ៊ីសូតូបដែលមានលក្ខណៈវិទ្យុសកម្ម ។

អ៊ីសូតូបដែលមានលក្ខណៈវិទ្យុសកម្ម ឬ**អ៊ីសូតូបវិទ្យុសកម្ម**បំបែកមិនទៀងទាត់ ។ យើងមិនអាចនិយាយបានថា អាតូម កាបូន-14 នឹងត្រូវបំបែកក្នុងរយៈពេលពីរបីវិនាទី ឬក៏រាប់ពាន់ឆ្នាំទៀតនោះទេ ប៉ុន្តែយើងដឹងច្បាស់ពីរយៈពេល

ដែលអ៊ីសូតូបវិទ្យុសកម្មក្នុងភាគសំណាកមួយបំបែកបានពាក់កណ្ដាល ។ រយៈពេលនេះឱ្យឈ្មោះថា **ពាក់កណ្ដាលខួប** ។

ពាក់កណ្ដាលខួបរបស់អាតូមកាបូន-14 មានរយៈពេល 5730 ឆ្នាំ ។ ដូច្នេះបើគេមានអាតូមកាបូន-14 ចំនួន 100 នោះគឺមាន 50 ក្នុងចំណោម 100 នឹងត្រូវបំបែករយៈពេល 5730 ឆ្នាំចាប់ពីពេលនេះតទៅ ។ លក្ខណៈនេះហើយដែលអាចជួយយើងឱ្យបកស្រាយអំពីអាយុរបស់ឈើ ឆ្អឹង និងសំលៀកបំពាក់បុរាណដែលភាគច្រើនមានអាតូមកាបូន-14 ដូច្នេះយើងអាចកំណត់អាយុរបស់វាបានតាមរយៈការវាស់កាំរស្មី ដែលគេឱ្យឈ្មោះថា**ការកំណត់អាយុរបស់កាបូន** ។

## ៣.៣ ម៉ាសអាតូមធៀប $A_r$ (ម៉ាសមធ្យម)

ដូចអ្នកបានដឹងរួចមកហើយថា អាតូមនៃធាតុគីមីតែមួយ៉ាងអាចមានម៉ាសធ្ងន់ស្រាលជាងគ្នាដោយសារអ៊ីសូតូបនឹងគ្នា ។ ម៉ាសធៀបនៃធាតុគីមីមួយគឺជាម៉ាសមធ្យមនៃអាតូមអ៊ីសូតូបរបស់វា ដែលគេតាងដោយ $A_r$ ។

*ឧទាហរណ៍* ប្រូមមានអ៊ីសូតូបធម្មជាតិពីរ

| **ឈ្មោះ** | **និមិត្តសញ្ញា** | **ចំនួនប្រូតុង** | **ចំនួនណឺត្រុង** | **ចំនួនម៉ាស** | **%អាតូមប្រូម** |
|---|---|---|---|---|---|
| ប្រូម-79 | $^{79}_{35}Br$ | 35 | 79-35=44 | 79 | 50% |
| ប្រូម-81 | $^{81}_{35}Br$ | 35 | 81-35=46 | 81 | 50% |



នៅក្នុងធម្មជាតិ ពាក់កណ្ដាលអាតូមប្រូមមានចំនួនណឺត្រុង44 ហើយមានចំនួនម៉ាស79 ។ ពាក់កណ្ដាលទៀតមានចំនួនណឺត្រុង 46 ហើយមានចំនួនម៉ាស81 ។ ដូច្នេះយើងអាចរកឃើញចំនួនម៉ាសមធ្យមរបស់ប្រូម គឺ 80 ។

## ៣.៤ របៀបរកម៉ាសអាតូមធៀប

យើងអាចប្រើរូបមន្តដើម្បីដោះស្រាយរកម៉ាសអាតូមធៀបដូចតទៅ ÷

ម៉ាសអាតូមធៀបនៃធាតុគីមីមួយ = ( % × ចំនួនម៉ាសអ៊ីសូតូបទីមួយ) + (% × ចំនួនម៉ាសអ៊ីសូតូបទីពីរ) "យើងធ្វើរបៀបនេះបន្តរហូតដល់អស់អ៊ីសូតូបធម្មជាតិរបស់វា " ។

*ឧទាហរណ៍* អាតូមក្លរមានអ៊ីសូតូបពីរនៅក្នុងធម្មជាតិ ។

| ឈ្មោះ | និមិត្តសញ្ញា | ចំនួនប្រូតុង | ចំនួនណឺត្រុង | ចំនួនម៉ាស | %អាតូមក្លរ |
|---|---|---|---|---|---|
| ក្លរ-35 | $^{35}_{17}Cl$ | 17 | 18 | 35 | 75% |
| ក្លរ-37 | $^{37}_{17}Cl$ | 17 | 20 | 37 | 25% |

ដោយប្រើរូបមន្តខាងលើ ម៉ាសមធ្យមរបស់អាតូមក្លរគឺ

$$Ar = \frac{75}{100} \times 35 + \frac{25}{100} \times 37$$

$$=26,25 + 9,25 = 35,5$$

ដូចនេះម៉ាសមធ្យម ឬ $A_r$ របស់អាតូមក្លរគឺ 35,5

## សំណួរ

1. អ្វីទៅជាអ៊ីសូតូប ? ចូរប្រាប់ឈ្មោះអ៊ីសូតូបនានារបស់អ៊ីដ្រូសែន និងសរសេរនិមិត្តសញ្ញារបស់វា។
2. តើអាតូមកាបូនមានអ៊ីសូតូបចំនួនប៉ុន្មាន?
3. អាតូមកាបូន-14មានលក្ខណៈវិទ្យុសកម្ម។ តើនេះមានន័យយ៉ាងដូចម្តេច ?
4. កាំរស្មីដែលចេញពីធាតុវិទ្យុសកម្មអាចមានគ្រោះថ្នាក់ ប៉ុន្តែពេលយើងដកដង្ហើម យើងបានស្រូបយកកាបូន-14មួយចំនួន។ តើហេតុអ្វីបានជាវាមិនប៉ះពាល់ដល់សុខភាពយើង?
5. តើសមាសភាពអ៊ីសូតូបរបស់ប្រូមយ៉ាងដូចម្តេច ? តើវាខុសប្លែកពីអ៊ីសូតូបនៃធាតុដទៃទៀតត្រង់ណា?
6. ទង់ដែងមានអ៊ីសូតូបពីរគឺ $^{63}_{29}Cu$ និង $^{65}_{29}Cu$

   ក- តើអ៊ីសូតូបនីមួយៗមានណឺត្រុងចំនួនប៉ុន្មាន ?

   ខ- គេដឹងថាអាតូមទង់ដែង-63 មានចំនួន69% ចូរគណនាម៉ាសអាតូមធៀបរបស់ទង់ដែង ។

# ៤ របៀបនៃការតម្រៀបអេឡិចត្រុង

## ៤.១ ស្រទាប់អេឡិចត្រុង

នៅក្នុងអាតូម អេឡិចត្រុងវិលយ៉ាងលឿនជុំវិញណ្វៃយ៉ូទៅតាមកម្រិតថាមពលខុសៗគ្នា។ កម្រិតថាមពលទាំងនេះឱ្យឈ្មោះថាស្រទាប់អេឡិចត្រុង។ ស្រទាប់ទីមួយនៅជិតណ្វៃយ៉ូមានកម្រិតថាមពលទាបជាងគេ (ថាមពលអេឡិចត្រុងតាំងនៅ)។ ស្រទាប់កាន់តែឆ្ងាយពីណ្វៃយ៉ូមានកម្រិតថាមពលកាន់តែខ្ពស់។ អេឡិចត្រុងទាំងឡាយតាំងនៅកម្រិតថាមពលទាបជាងគេដែលទំនេរ ។ប៉ុន្តែវាទាំងអស់គ្នាមិនអាចតាំងនៅស្រទាប់ទីមួយបានទេ។ ព្រោះស្រទាប់មួយអាចតាំងនៅបានត្រឹមតែចំនួនអេឡិចត្រុងកំណត់ណាមួយប៉ុណ្ណោះ។

*ឧទាហរណ៍*



ដូច្នេះអេឡិចត្រុងត្រូវបំពេញតាមស្រទាប់មួយម្ដងៗ ដោយចាប់ផ្ដើមពីស្រទាប់ទីមួយ នៅពេលស្រទាប់មួយមុនត្រូវបានបំពេញគ្រប់ ទើបស្រទាប់បន្ទាប់ទៀតចាប់ផ្ដើម។

## ៤.២ ស្រទាប់អេឡិចត្រុងរបស់ធាតុ 20ដំបូង

| ធាតុគីមី | និមិត្តសញ្ញា | លេខលំដាប់ ឬលេខអាតូម | ស្រទាប់ទី១ | ស្រទាប់ទី២ | ស្រទាប់ទី៣ | ស្រទាប់ទី៤ |
|---|---|---|---|---|---|---|
| អ៊ីដ្រូសែន | H | 1 | 1 | | | |
| អេល្យ៉ូម | He | 2 | 2 | | | |
| លីចូម | Li | 3 | 2 | 1 | | |
| បេរីល្យ៉ូម | Be | 4 | 2 | 2 | | |
| បរ | B | 5 | 2 | 3 | | |
| កាបូន | C | 6 | 2 | 4 | | |
| អាសូត | N | 7 | 2 | 5 | | |
| អុកស៊ីសែន | O | 8 | 2 | 6 | | |
| ភ្លុយអរ | F | 9 | 2 | 7 | | |
| នេអុង | Ne | 10 | 2 | 8 | | |
| សូដ្យូម | Na | 11 | 2 | 8 | 1 | |
| ម៉ាញ៉េស្យូម | Mg | 12 | 2 | 8 | 2 | |
| អាលុយមីញ៉ូម | Al | 13 | 2 | 8 | 3 | |
| ស៊ីលីស្យូម | Si | 14 | 2 | 8 | 4 | |
| ផូស្វ័រ | P | 15 | 2 | 8 | 5 | |
| ស្ពាន់ធ័រ | S | 16 | 2 | 8 | 6 | |
| ក្លរ | Cl | 17 | 2 | 8 | 7 | |
| អាកុង | Ar | 18 | 2 | 8 | 8 | |
| ប៉ូតាស្យូម | K | 19 | 2 | 8 | 8 | 1 |
| កាល់ស្យូម | Ca | 20 | 2 | 8 | 8 | 2 |

មានតែអាតូមបី (អេល្យូម នេអុង និងអាកុង) ក្នុងចំណោមធាតុគីមី20ដំបូង ដែលមានអេឡិចត្រុងពេញនៅស្រទាប់ខាងក្រៅបង្អស់។ ដោយលក្ខណៈនេះហើយដែលធ្វើឱ្យវាមិនមានប្រតិកម្ម (ធាតុនិចល) ដូចដែលអ្នកនឹងបានឃើញនៅផ្នែកខាងក្រោយ។

## ៤.៣ គ្រោងអេឡិចត្រុង និងតារាងខួប

គ្រោងអេឡិចត្រុងមានន័យថា ជាតម្រៀបអេឡិចត្រុងនៅក្នុងអាតូមមួយ ។គ្រោងអេឡិចត្រុងរបស់ធាតុ20ដំបូងត្រូវ បានបង្ហាញដូចខាងក្រោមទៅតាមតារាងខួបជាជួរដេក និងជួរឈរ(ខួប និងក្រុម) ÷




**ចំណាំ**

- ស្រទាប់ទាំងឡាយត្រូវបំពេញដោយអេឡិចត្រុងនៅតាមលំដាប់ ដោយចាប់ផ្តើមពីស្រទាប់ដែលមានកម្រិតថាមពលទាប ជាងគេបំផុត។
- គ្រប់ធាតុគីមីទាំងអស់នៅក្នុងក្រុមដូចគ្នា មានចំនួនអេឡិចត្រុងស្រទាប់ក្រៅដូចគ្នា។
- លេខក្រុមស្មើនឹងចំនួនអេឡិចត្រុងនៅស្រទាប់ក្រៅ។
- ធាតុគីមីនៅក្នុងក្រុមសូន្យ (ឧស្ម័នកម្រ) មានអេឡិចត្រុងឆ្អែត(ពេញ)នៅគ្រប់ស្រទាប់។
- លេខខួបស្មើនឹងចំនួនស្រទាប់អេឡិចត្រុងដែលវាមាន។

**សំណួរ**

1. អាតូមមួយមានអេឡិចត្រុងចំនួន 13 ។ ចូរគូសគំនូសតាងបង្ហាញពីការតម្រៀបអេឡិចត្រុងរបស់វា ។ តើវាជាធាតុអ្វី ?
2. ដូចម្តេចដែលហៅថាគ្រោងអេឡិចត្រុង?
3. គ្រោងអេឡិចត្រុងរបស់សូដ្យូមគឺ 2,8,1 ។ ចូរបង្ហាញពីគ្រោងអេឡិចត្រុងរបស់ធាតុខាងក្រោមនេះ ។
   ក- លីចូម? ខ- ម៉ាញេស្យូម? គ- អ៊ីដ្រូសែន?
4. អាតូមមួយមានអេឡិចត្រុងនៅស្រទាប់ខាងក្រៅចំនួន៥ ។ តើវាស្ថិតនៅក្រុមណាក្នុងតារាងខួប?
5. តើអាតូមនៅក្នុងខួបទី៣មានស្រទាប់អេឡិចត្រុងចំនួនប៉ុន្មាន?
6. ក្នុងចំណោមធាតុគីមីទាំង២០ដំបូង តើធាតុណាខ្លះដែលមានអេឡិចត្រុងស្រទាប់ក្រៅបង្អស់ឆ្អែត(ពេញ)? ចូរសរសេរគ្រោងអេឡិចត្រុងរបស់ធាតុទាំងនោះ ។

# ៥ ទស្សនៈបន្តបន្ទាប់អំពីអាតូម

## ៥.១ ការសិក្សាឡើងវិញ

ទស្សនៈសំខាន់ជាងគេបង្អស់របស់គីមីគឺគ្រប់វត្ថុទាំងអស់ធ្វើឡើងដោយអាតូម ។ ដូច្នេះនៅពេលគេរៀបចំអ្វីមួយនៅទីពិសោធគេពិតជាធ្វើវាឡើងដោយឱ្យភាគល្អិតអាតូមរាប់រយកោដិមានប្រតិកម្មជាមួយគ្នា ។តើគីមីវិទូរកឃើញអាតូមដោយរបៀបណា? មានប្រវត្តិវែងឆ្ងាយណាស់ ។

### ៥.១.១ ទស្សនៈរបស់ជនជាតិក្រិចបុរាណ

ទស្សនវិទូជនជាតិក្រិចជាច្រើនបានគិតពីពិភពជុំវិញខ្លួនរបស់ពួកគេ ។ តើទឹកគឺជារូបធាតុដែលមិនអាចបំបែកបានឬ? តើខ្យល់គ្រាន់តែជាលំហទទេឬ? បើយើងបំបែកថ្មមួយដុំឱ្យទៅជាផង់ បន្ទាប់មកបំបែកផង់នោះទៀត តើចុងក្រោយយើងនឹងអាចបំបែកបានភាគល្អិតតូចជាងនេះទៀតដែរឬទេ?

ប្រហែល 450ឆ្នាំមុនគ្រិស្តសករាជ ទស្សនវិទូម្នាក់ឈ្មោះដេម៉ូគ្រីត (Democritus) បានលើកឡើងនូវសម្មតិកម្មមួយដែលចែងថា "គ្រប់វត្ថុទាំងអស់បង្កើតឡើងដោយភាគល្អិតតូចៗ ដែលមិនអាចបំបែកបានហៅថា**អាតូម**"ដែលមានន័យថា"មិនអាចបំបែកតទៅទៀតបាន" ។ គាត់សន្មតទៅលើអាតូមដោយពណ៌បួនគឺ ស ខ្មៅ ក្រហម និងបៃតងហើយមានរូបរាង និងទំហំខុសៗគ្នា ។ មិនតែប៉ុណ្ណោះ គាត់បានសន្មតទៀតថា អាតូមដែលមានរូបរាងមូលហើយធំមានរសជាតិផ្អែម រីឯអាតូមមានរូបរាងស្រួចហើយតូចមានរសជាតិជូរ ។ អាតូមពណ៌សមានលក្ខណៈរលោង ចំណែកឯអាតូមពណ៌ខ្មៅមានលក្ខណៈ គ្រើម ។ គ្រប់វត្ថុក្នុងលោកបង្កើតពីល្បាយ អាតូមទាំងនេះ តាមបរិមាណផ្សេងៗគ្នា ។

ទស្សនវិទូផ្សេងទៀតបានគិតថាទស្សនៈនេះមិនសមហេតុផលទេ ។ លោកអារីស្តូថល (Aristotle)(384-270មុនគ្រិស្តសករាជ) គិតថាវត្ថុគ្រប់យ៉ាងបង្កើតពីធាតុបួនយ៉ាងគឺ ទឹក ដី ភ្លើង និងខ្យល់ ដែលត្រូវបានលាយបញ្ចូលគ្នាតាម

បរិមាណខុសៗគ្នា ។ថ្មមួយដុំមានដីច្រើន ប៉ុន្តែមិនមានទឹកច្រើនទេ ។ ទោះបីជាគេបំបែកវាទៅជាផង់តូចៗយ៉ាងណាក៏ដោយ ក៏ផង់ ទាំងនេះនៅតែរក្សាលក្ខណៈរបស់ថ្មដដែល ។

## ៥.១.២ ទស្សនៈរបស់អ្នកគីមីមជ្ឈឹមសម័យ

ទស្សនវិទូជនជាតិក្រិចបានខិតខំគិតយ៉ាងខ្លាំងអំពីបញ្ហាខាងលើនេះប៉ុន្តែមិនបានធ្វើពិសោធន៍ទេ ។ អ្នកគីមីមជ្ឈឹមសម័យ (1400-1650 ក្រោយគ្រិស្តសករាជ) បានយល់ឃើញផ្សេងពីនេះ ពួកគាត់បានធ្វើពិសោធន៍ ទាំងថ្ងៃ ទាំងយប់ក្នុងគោលបំណងរកឱ្យឃើញស្រាទក្សាជីវិត (រក្សារូបរាងឱ្យនៅតែក្មេង)និងខំប្រឹងបង្កើតមាសចេញពីលោហៈដែលមានតម្លៃថោក ។ អ្នកគីមីមជ្ឈឹមសម័យបានជឿថាអ្វីៗគ្រប់យ៉ាងផ្សំឡើងពីធាតុបីយ៉ាងមាន បារត ស្ពាន់ធ័រ និងអំបិល ។ អ្នកអាចបំលែងលោហៈមូលដ្ឋានដូចជាសំណឱ្យទៅជាមាសដោយគ្រាន់តែបន្ថែមបរិមាណបារតឱ្យបានត្រឹមត្រូវតែប៉ុណ្ណោះ ។ ចុងក្រោយមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ ដោយពួកគេមិនបានទទួលជោគជ័យក្នុងការផលិតមាស ។ ប៉ុន្តែគេបានផលិតសារធាតុជាច្រើនដែលមានលក្ខណៈស្រដៀងនឹងដូចមាស ដោយប្រើរូបមន្តអាថិកំបាំងស្រោបសមាសធាតុផ្សេងៗទៅលើផ្ទៃសារធាតុរបស់ពួកគេប្រើប្រាស់ ។

## ៥.១.៣ របកគំហើញរបស់គីមីវិទូ

នៅទីបញ្ចប់ អ្នកគីមីមជ្ឈឹមសម័យមានកេរ្តិ៍ឈ្មោះដោយសារការបន្លំ និងភូតកុហស ឆបោកប្រាក់រង្វាន់ពីសេដ្ឋីដែលចង់បានមាស ។ ជាយថាហេតុពួកគេបានផ្តល់ឱកាសសម្រាប់ការកើតមាននូវប្រភេទអ្នកគីមីត្រឹមត្រូវ ។ នៅពេលនោះការយល់ដឹងអំពីអាតូមស្ទើរតែត្រូវបានបំភ្លេចទៅហើយ ។ ប៉ុន្តែនៅឆ្នាំ 1661 អ្នកវិទ្យាសាស្ត្រឈ្មោះរ៉ូប៊ែតប៊យ (Robert Boyle) បានបង្ហាញថា ឧស្ម័នអាចត្រូវបណ្ណែនឱ្យកាន់តែមានលំហតូច ។ គាត់សន្និដ្ឋានថា ឧស្ម័នបង្កដោយភាគល្អិតដែលមានចន្លោះលំហរវាងគ្នានឹងគ្នា (គាត់ក៏បានលើកឡើងពីនិយមន័យនៃធាតុដែលនៅតែប្រើបានរហូតមកដល់សព្វថ្ងៃនេះ ÷ *ធាតុគឺជាសារធាតុដែលមិនអាច បំបែកឱ្យទៅជាសារធាតុងាយជាងនេះបាន*) ។

នៅឆ្នាំ 1799 ហើយជាង 130 ឆ្នាំក្រោយមក គីមីវិទូជនជាតិបារាំងឈ្មោះហ្សូសែបល្វីព្រុស្ត (Joseph Louis Proust) បានបង្ហាញឱ្យឃើញថា ទង់ដែង(II) កាបូណាតមានសមាមាត្រដូចគ្នារវាងទង់ដែង កាបូន និងអុកស៊ីសែន ។ ទោះបីជាយើងផលិតវាតាមរបៀបណាក៏ដោយ ក៏សមាមាត្រភាគផ្សំរបស់វានៅតែៈ 5ភាគទង់ដែងទល់នឹង 2 ភាគកាបូន និង 1 ភាគអុកស៊ីសែន ។ នេះនាំឱ្យយើងសន្និដ្ឋានថាទង់ដែង កាបូន និងអុកស៊ីសែនបង្កឡើងពីភាគល្អិតដែលផ្សំជាមួយគ្នាតាមផលធៀបដូចៗគ្នា ។

## ៥.១.៤ ទស្សនៈរបស់ដាល់តុន (Dalton)

គីមីវិទូជនជាតិអង់គ្លេស ឈ្មោះ ដាល់តុន (Dalton) បានវិភាគទៅលើរបកគំហើញទាំងនេះ ។ ក្នុងឆ្នាំ 1803 គាត់បានសន្និដ្ឋានថា បើសិនធាតុទាំងអស់ពិតជាបង្កពីភាគល្អិតដែលមិនអាចបំបែកបានមែននោះ ដូច្នេះអ្វីៗទាំងអស់ពិតជាត្រឹមត្រូវហើយ ។ គាត់បានឱ្យឈ្មោះភាគល្អិតនេះថា**អាតូម** តាមជនជាតិក្រិច ។ បណ្តាអាតូមរបស់ធាតុមួយអាចផ្សំជាមួយបណ្តាអាតូមនៃធាតុផ្សេងទៀតតាមផលធៀបជាក់លាក់មួយ ។ ពេលនេះគំនិតពីអាតូមកាន់តែយល់ច្បាស់តាមរយៈពិសោធន៍ជាច្រើន ។

### ៥.១.៥ លំញ័ររបស់លំអងធញ្ញជាតិ

គ្មាននរណាម្នាក់បញ្ជាក់ឱ្យឃើញថារូបធាតុបង្កើតឡើងពីភាគល្អិតដាច់ៗពីគ្នានោះទេ ដោយសារវាតូចពេកពិបាកមើលឃើញដោយភ្នែកទទេ។ ប៉ុន្តែក្នុងឆ្នាំ 1827 រុក្ខវិទូជនជាតិស្កុតឡែនឈ្មោះរ៉ូបែតប្រោន (Robert Brown) បានសិក្សាពីលំអងធញ្ញជាតិនៅក្នុងទឹកដោយមានការឆ្លុះមីក្រូទស្សន៍ផង គាត់ឃើញថាវាធ្វើចលនាឥតឈប់ឈរ ហើយគាត់គិតទៀតថាវាមានជីវិត បន្ទាប់មកគាត់សាកល្បងជាមួយលំអងធូលីម្តង វាក៏មានចលនាដូចគ្នា។ គាត់សន្និដ្ឋានថាលំអងធ្វើចលនាបាន ដោយសារការរុញច្រានពីភាគល្អិតរបស់ទឹក។ ដូច្នេះពិតជាមានភាគល្អិតដាច់ៗពីគ្នាមែន មិនមែនមានតែនៅក្នុងទ្រឹស្តីនោះទេ។

### ៥.១.៦ ទស្សនៈបន្តបន្ទាប់មក...

នៅក្នុងឆ្នាំ 1955 ជនជាតិអាមេរិចឈ្មោះ អឺវិន មុលឺ (Erwin Muller) បានបង្កើតម៉ាស៊ីនមួយមានឈ្មោះថាមីក្រូទស្សន៍ពីនិត្យអ៊ីយ៉ុង ដែលវាអាចពង្រីករូបភាពចុងម្ជុលម៉ាញេទិចបាន៥លានដង។ បច្ចុប្បន្ននេះមីក្រូទស្សន៍អេឡិចត្រូនិចបានបង្ហាញរូបភាពដ៏អស្ចារ្យពីអាតូមផ្សេងៗគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ តាមការសិក្សាអស់រយៈពេលជាច្រើនទសវត្សមកហើយ អ្នកវិទ្យាសាស្ត្របានឆ្ងល់ថា តើមានអ្វីនៅក្នុងអាតូម។ នេះគឺជារឿងមួយផ្សេងទៀត។

### សំណួរ

1. តាមទស្សនៈរបស់លោកដេម៉ូគ្រីត ចូររៀបរាប់ពីអាតូមនានាដែលអ្នកជឿជាក់ថាមាននៅក្នុងទឹកក្រូចកូកាកូឡាមួយកំប៉ុង។
2. តើលោក ដេម៉ូគ្រីត យល់ឃើញត្រឹមត្រូវយ៉ាងដូចម្តេចអំពីអាតូម?
3. តើមានរយៈពេលប៉ុន្មានឆ្នាំនៅចន្លោះរវាងពំនោលរបស់ដេម៉ូគ្រីត និងដាល់តុនស្តីអំពីអាតូម?
4. ហេតុអ្វីបានជាលោក ដាល់តុន យល់ថាទស្សនៈរបស់គាត់ពីអាតូមត្រូវបានគេទទួលយក មិនដូចទស្សនៈរបស់លោកដេម៉ូគ្រីតនៅពេលនោះទេ?
5. របកគំហើញដែលថា លំអងធញ្ញជាតិនៅក្នុងទឹកមានលំញ័រ ជាដំណាក់កាលសំខាន់ក្នុងផ្នែកវិទ្យាសាស្ត្រ។ ហេតុអ្វី?
6. ហេតុអ្វីបានជាលំអងធូលីធ្វើចលនានៅក្នុងខ្យល់ដែរ?

# ៦ ប្រវត្តិរបកគំហើញភាគល្អិតបង្កអាតូម

## ៦.១ ផ្តើមចេញពីរូបវិទ្ធ

200ឆ្នាំមកហើយ គីមីវិទូបានទទួលស្គាល់ថា វត្ថុគ្រប់យ៉ាងផ្សំឡើងដោយភាគល្អិតដ៏តូចបំផុត ដែលមិនអាចបំបែកបានហៅថា "អាតូម" ប៉ុន្តែបច្ចុប្បន្ននេះគេដឹងថាអាតូមអាចបំបែកបាន។ ប្រហែលជា 100 ឆ្នាំចុង



គំរូអាតូមរបស់លោក ដាល់តុន

ក្រោយនេះ គេបានសិក្សាយ៉ាងស៊ីជម្រៅពីភាគល្អិតដែលមាននៅក្នុងអាតូម ។

## ៦.២ របកគំហើញអេឡិចត្រុង



គំរូអាតូមរបស់លោក ថូមសុន

ក្នុងឆ្នាំ 1897 រូបវិទូជនជាតិអង់គ្លេសម្នាក់ឈ្មោះ ថូមសុន (J.J Thomson) បានសង្កេតមើលកាំរស្មីកាតូត ជាកាំរស្មីមានពន្លឺលេចឡើងក្នុងបំពង់កែវសុញ្ញាកាសមួយដែលត្រូវបានតភ្ជាប់ទៅនឹងសៀគ្វីអគ្គិសនី ។ គាត់សន្និដ្ឋានថា កាំរស្មីនេះ ការពិតគឺជាបាច់នៃភាគល្អិតមានបន្ទុក ដែលតូចជាងអាតូមខ្លាំង ហើយវាជាផ្នែកមួយនៃអាតូម។ គាត់ឱ្យឈ្មោះភាគល្អិតនោះថា **គ្រាប់ល្អិតអាតូម** (corpuscles) ហើយក្រោយមកឈ្មោះនេះត្រូវបានប្តូរទៅជា **អេឡិចត្រុង** ។

វាជារឿងភ្ញាក់ផ្អើលមួយដែលថាអាតូមមិនមែនជាភាគល្អិតតូចជាងគេបង្អស់ទៀតទេ ។ លោកថូមសុនបានឱ្យយោបល់ថា អេឡិចត្រុងស្ថិតនៅស្អិតជាប់នឹងអាតូម ដូចជាគ្រាប់ទំពាំងបាយជូរស្ងួតដែលស្អិតជាប់ដុំនំដែរ ហើយផ្នែកនៅសល់នៃអាតូមមានបន្ទុកវិជ្ជមាន ។

## ៦.៣ កាំរស្មីចម្លែក

មុននោះមួយឆ្នាំ រូបវិទូជនជាតិបារាំងម្នាក់ឈ្មោះ បិចគឺរ៉ែល (Becquerel) បានសង្កេតឃើញវត្ថុមួយមាន លក្ខណៈចម្លែកយ៉ាងខ្លាំង ដោយគាត់បានឃើញបន្ទះហ្វីលរូបថតដែលគេទុកក្នុងថតតុឡើងស្រអាប់ដោយសារប៉ះនឹងកាំរស្មី ចម្លែក ។ បាតុភូតនេះបណ្តាលមកពីភាគសំណាកអ៊ុយរ៉ាញ៉ូមដែលដាក់នៅក្នុងថតតុនោះដែរ ។ហេតុការណ៍នេះបានធ្វើឱ្យគាត់រកឃើញនូវបាតុភូតវិទ្យុសកម្មភាព ។ អ៊ុយរ៉ាញ៉ូមបញ្ចេញភាគល្អិតអាល់ហ្វា (ឥឡូវនេះយើងដឹងថាភាគល្អិតនេះជា បណ្តុំនៃប្រូតុងពីរ និងណឺត្រុងពីរ) ដែលមានសារៈប្រយោជន៍បំផុត ។ វាមានបន្ទុកវិជ្ជមាន ហើយធ្ងន់ជាងអេឡិចត្រុង 7000 ដង ។គេអាចពន្លឿនល្បឿនវា និងបាញ់វាដូចជាគ្រាប់កាំភ្លើងដ៏តូចឆ្មារ ។

## ៦.៤ ណ្វៃយ៉ូ និងប្រូតុង


គំរូអាតូមរបស់លោក រ៉ូធឺផត


គំរូអាតូមរបស់លោក ប

ក្នុងឆ្នាំ 1911 នៅប្រទេសអង់គ្លេស រូបវិទូម្នាក់ឈ្មោះ អឺនណែស្ត៍រ៉ូធឺផត (Ernest Rutherford) បានពិសោធដោយប្រើភាគល្អិតអាល់ហ្វា ។ គាត់បានបាញ់បាច់ភាគល្អិតអាល់ហ្វាទៅលើសន្លឹកស្តើងនៃមាស ។ គាត់សង្កេតឃើញភាគល្អិតអាល់ហ្វាភាគច្រើនបានឆ្លងកាត់សន្លឹកមាសនោះ ប៉ុន្តែភាគល្អិតខ្លះបានផ្លាតមកវិញ ។ លោករ៉ូធឺផតបានពន្យល់ថាអាតូមស្ទើរតែជាលំហទទេ ដែលភាគល្អិតអាល់ហ្វាស្ទើរតែទាំងអស់អាចឆ្លងកាត់បាន ដោយងាយស្រួល ។ ប៉ុន្តែវាមានអ្វីមួយតូច ធ្ងន់ នៅចំកណ្តាល ដែលអាចធ្វើឱ្យភាគល្អិតអាល់ហ្វាខ្លះផ្លាតមកវិញ ។ គាត់បានរកឃើញ **ណ្វៃយ៉ូ** ដោយសន្មតថា វាផ្សំដោយភាគល្អិតដែលមានបន្ទុកវិជ្ជមាន ហៅថា **ប្រូតុង** ។

## ៦.៥ ស្រទាប់អេឡិចត្រុង

ប្រសិនបើណ្វៃយ៉ូមានបន្ទុកវិជ្ជមាន ហេតុអ្វីបានជាអេឡិចត្រុងមិនរត់ទៅរកវា? ក្នុងឆ្នាំ 1913 លោក នេលប័រ (Niels Bohr) បានលើកឡើងពីទ្រឹស្តីស្រទាប់អេឡិចត្រុង។ ទ្រឹស្តីរបស់គាត់ត្រឹមត្រូវគ្រប់ពិសោធន៍ទាំងអស់។



គំរូអាតូមរបស់លោក ឆាតវិច

## ៦.៦ ណឺត្រុង

ក្នុងឆ្នាំ 1930 រូបវិទូជនជាតិអាល្លឺម៉ង់ពីរនាក់ ឈ្មោះ ប៊ូត និងប៊ែកឃើរ (Bothe and Becker) បានបាញ់ភាគល្អិតអាល់ហ្វាទៅលើបេរីល្យូម ហើយបានបំបែកដុំភាគល្អិតថ្មីចេញពីបន្ទះបេរីល្យូមនោះ។ នៅឆ្នាំ 1932 រូបវិទូជនជាតិអង់គ្លេសឈ្មោះ ចែមឆាតវិច (James Chadwick) បានយល់ឃើញថា ភាគល្អិតទាំងនេះមានម៉ាសស្មើម៉ាសប្រូតុងដែរ ប៉ុន្តែគ្មានបន្ទុក ហើយគាត់ឱ្យឈ្មោះថា **ណឺត្រុង**។ 129 ឆ្នាំបន្ទាប់ពី លោក ដាល់តុន (Dalton) បានស្នើគំរូអាតូមមក គំរូអាតូមនេះត្រូវបានបំពេញបន្ថែមដោយគីមីវិទូក្រោយៗមកទៀត។

## ៦.៨ ភាពពិត

ឥឡូវនេះ តើការសិក្សាអំពីអាតូមចប់សព្វគ្រប់ហើយឬនៅ? គំរូអាតូមដែលអ្នកបានប្រើពន្យល់យ៉ាងច្បាស់សម្រាប់អ្នកគីមី ដើម្បីពន្យល់ពីលក្ខណៈសំគាល់នៃធាតុ។ ប៉ុន្តែវាគ្រាន់តែជាគំរូមួយ ដែលជាគំនូសតាងងាយប៉ុណ្ណោះ។ តាមពិតអាតូមមានភាពសាំញ៉ាំច្រើនជាងគំរូរបស់យើងទៅទៀត។ រូបវិទូបានរកឃើញថាមានភាគល្អិតងាយខុសៗគ្នាចំនួនប្រហែល 50 មុខទៀតនៅក្នុងអាតូម។ វាអាចនឹងមានអ្វីៗច្រើនជាងនេះទៀតដើម្បីរុករក។

### សំណួរ

1. លោកដាល់តុន បានស្នើទស្សនៈរបស់គាត់អំពីអាតូមក្នុងឆ្នាំ 1803។ តើប៉ុន្មានឆ្នាំក្រោយមកទៀត ទើបគេរកឃើញអេឡិចត្រុង?
2. ជារឿយៗរបកគំហើញនៅក្នុងវិទ្យាសាស្ត្រមិនមែនជាកិច្ចការរបស់មនុស្សតែម្នាក់ទេដែលធ្វើ គឺមានមនុស្សជាច្រើនដែលចូលរួម។ តើនរណាជាអ្នករកឃើញ ÷

   ក- អេឡិចត្រុង? ខ- ណ្វៃយ៉ូ? គ- ណឺត្រុង?
3. ក- អ្វីដែលអ្នកបានរៀនក្នុងផ្នែកគីមីអំពីអាតូម គឺជាគំរូងាយៗ។ ចូរពន្យល់។

   ខ- ហេតុអ្វីបានជាអ្នកគីមីបន្តប្រើគំរូនេះ ?

# សំណួរ និងលំហាត់សម្រាប់មេរៀនទី១

1. ខាងក្រោមនេះគឺជាសារធាតុគីមីសាមញ្ញមួយចំនួន។

*ដែក  កាបូនឌីអុកស៊ីត  បារត  សូដ្យូមក្លរួ  ទឹក  អ៊ីដ្រូសែន*

ក i- ចូរចែកសារធាតុទាំងនេះជាពីរផ្នែក ÷ ធាតុ និងសមាសធាតុ ។

ii- ដោយប្រើទស្សនៈនៃអាតូម ចូរពន្យល់ពីភាពខុសគ្នារវាងធាតុ និងសមាសធាតុ ។

ខ- ចូរចែកធាតុទាំងនេះជាលោហៈ និងអលោហៈ

គ- ចូរផ្ដល់ឧទាហរណ៍ពីរបន្ថែមទៀតអំពី ÷

i- លោហៈ

ii- អលោហៈ

iii- សមាសធាតុ

2. ក្នុងម៉ូលេគុលទឹក អាតូមត្រូវបានភ្ជាប់គ្នាដូចបានបង្ហាញក្នុងរូបនេះ




តើអាតូមក្នុងសមាសធាតុខាងក្រោមនេះភ្ជាប់គ្នាយ៉ាងដូចម្ដេច?

ក- ស្ពាន់ធ័រឌីអុកស៊ីត $SO_2$

ខ- មេតាន $CH_4$

គ- មេតាណុល $CH_4O$

ឃ- អ៊ីដ្រូសែនពែអុកស៊ីត $H_2O_2$

ង- អាម៉ូញាក់ $NH_3$

3. បើ **p** តាងឱ្យប្រូតុង **e** តាងឱ្យអេឡិចត្រុង និង **n** តាងឱ្យណឺត្រុង តើការរៀបរាប់ខាងក្រោមនេះត្រូវនឹងភាគល្អិតណាមួយ?

ក-ភាគល្អិតដែលមានបន្ទុកវិជ្ជមាន ។

ខ-ភាគល្អិតដែលមាននៅជាមួយប្រូតុងក្នុងណ្វៃយ៉ូ ។

គ-ភាគល្អិតដែលមានចំនួនខុសគ្នានៅក្នុងអាតូមពីរនៃធាតុតែមួយ ។

ឃ-ភាគល្អិតដែលវិលជុំវិញណ្វៃយ៉ូ ។

ង-ភាគល្អិតដែលមានបន្ទុកអវិជ្ជមាន ។

ច-ភាគល្អិតដែលម៉ាសរបស់វាអាចចោលបាន ។

ឆ-ភាគល្អិតដែលចំនួនវាបានមកពីផលដកនៃចំនួនម៉ាស និងលេខលំដាប់ ។

ជ-ភាគល្អិតដែលគ្មានបន្ទុក ។

ឈ-ភាគល្អិតដែលមានម៉ាសស្មើទៅនឹងម៉ាសណឺត្រុង ។

ញ-ភាគល្អិតដែលមានចំនួនស្មើលេខលំដាប់ ។

4. អាតូមនៃធាតុមួយត្រូវបានបង្ហាញដូចនេះ $^{Y}_{z}X$

ក- តើ $X$ $Y$ និង $Z$ តាងឱ្យអ្វី?

ខ- តើអាតូមនីមួយៗខាងក្រោមនេះមានណឺត្រុងប៉ុន្មាន?

$^{107}_{47}Ag$ $^{63}_{29}Cu$ $^{1}_{1}H$ $^{20}_{10}Ne$ $^{238}_{92}U$

5. អ៊ីដ្រូសែន ដឺតេរ្យ៉ូម និងទ្រីចូម ជាអ៊ីសូតូបនឹងគ្នា។ ទម្រង់របស់វាត្រូវបានបង្ហាញដូចខាងក្រោម ÷



អ៊ីដ្រូសែន ដឺតេរ្យ៉ូម ទ្រីចូម

ក- ដោយមើលរូប ចូរបំពេញចន្លោះខាងក្រោម ÷

× តាងឱ្យ .......................

○ តាងឱ្យ .......................

⊗ តាងឱ្យ .......................

ខ- តើចំនួនម៉ាសអាតូមអ៊ីដ្រូសែន ដឺតេរ្យ៉ូម និងទ្រីចូមមានប៉ុន្មាន ?

គ- ចូរបំពេញល្បះដូចតទៅនេះ ÷ អ៊ីសូតូបរបស់ធាតុមួយតែងតែមានចំនួន..................និង.......... ស្មើគ្នា ប៉ុន្តែចំនួន............................... ខុសគ្នា។

ឃ- ចំនួនម៉ាសមធ្យមអ៊ីដ្រូសែនក្នុងធម្មជាតិគឺ 1,008 ។ តើអ៊ីសូតូបណាមួយដែលមានសមាមាត្រភាគរយច្រើនជាងគេបំផុត?

6. ចូរបំពេញតារាងអ៊ីសូតូបរបស់ធាតុងាយៗមួយចំនួន ដូចខាងក្រោម ÷

| **អ៊ីសូតូប** | **ឈ្មោះធាតុគីមី** | **ចំនួនប្រូតុង** | **ចំនួនម៉ាស** | **ចំនួន** | | |
|---|---|---|---|---|---|---|
| | | | | **p** | **e** | **n** |
| $^{16}_{8}O$ | អុកស៊ីសែន | 8 | 16 | 8 | 8 | 8 |
| $^{18}_{8}O$ | | | | | | |
| $^{12}_{6}C$ | | | | | | |
| $^{13}_{6}C$ | | | | | | |
| $^{24}_{12}Mg$ | | | | | | |
| $^{25}_{12}Mg$ | | | | | | |
| | | | | 17 | 17 | 18 |
| | | | | 17 | 17 | 20 |

7. ចំពោះធាតុទាំង 6 នេះ ÷ អាលុយមីញ៉ូម (Al) បរ (B) អាសូត (N) អុកស៊ីសែន (O) ផូស្វរ (P) និងស្ពាន់ធ័រ (S) ។ ចូរបញ្ជាក់ ÷

ក- ខួបរបស់ធាតុនីមួយៗ នៅក្នុងតារាងខួប ។

ខ- ក្រុមរបស់ធាតុនីមួយៗនៅក្នុងតារាងខួប ។

គ- លេខលំដាប់របស់ធាតុនីមួយៗនៅក្នុងតារាងខួប ។

ឃ- ចំនួនអេឡិចត្រុងដែលមាននៅក្នុងអាតូមនីមួយៗ ។

ង- គ្រោងអេឡិចត្រុងរបស់ធាតុនីមួយៗ ។

ច- ចំនួនអេឡិចត្រុងស្រទាប់ក្រៅបង្អស់របស់អាតូមនីមួយៗ ។ ក្នុងចំណោមធាតុខាងលើតើណាខ្លះដែលអ្នកជឿថាមានលក្ខណៈស្រដៀងគ្នា? ហេតុអ្វី?

8. បរមានអាតូមពីរប្រភេទដូចបង្ហាញក្នុងរូបខាងក្រោម ÷




ក- តើអាតូមទាំងពីរខាងលើនេះជាអ្វីនឹងគ្នា?

ខ- ចូរសរសេរសណ្ឋានកាត់របស់អាតូមនីមួយៗ?

គ- តើចំនួនម៉ាសរបស់អាតូម A ប៉ុន្មាន?

ឃ- ហេតុអ្វីបានជាចំនួនម៉ាសអាតូម A និងអាតូម B ខុសគ្នា? តើអាតូម B ធ្ងន់ជាងឬស្រាលជាងអាតូម A?

ង- ចូរសរសេរគ្រោងអេឡិចត្រុងអាតូម A និង B? ចូរពន្យល់?

ច- ក្នុងធម្មជាតិអាតូម B មាន 80% ។ ចូរគណនាម៉ាសអាតូមធៀប(មធ្យម)របស់បរ ។

9. កាល្យ៉ូម (Ga) មាននៅក្នុងធម្មជាតិ ជាទូទៅផ្សំឡើងពីល្បាយនៃអ៊ីសូតូបពីរយ៉ាងគឺ កាល្យ៉ូម-69 និងកាល្យ៉ូម-71 ។ លេខលំដាប់របស់អាតូមកាល្យ៉ូម គឺ 31 ។

ក- តើកាល្យ៉ូម-69 មានចំនួនណឺត្រុងប៉ុន្មាន? តើកាល្យ៉ូម-71 មានចំនួនណឺត្រុងប៉ុន្មាន?

ខ- គណនាភាគរយអ៊ីសូតូបនីមួយៗរបស់កាល្យ៉ូមនៅក្នុងធម្មជាតិ (ម៉ាសអាតូមធៀប(មធ្យម)កាល្យ៉ូមគឺ 69,8) ។

10. នៅក្នុងតារាងខួបសូដ្យូមមានលេខលំដាប់11 និងម៉ាញេស្យូមមានលេខលំដាប់ 12 ។

ក- តើលោហៈទាំងពីរនេះមានចំនួនស្រទាប់អេឡិចត្រុង និងចំនួនអេឡិចត្រុងនៅស្រទាប់ក្រៅដូចគ្នា ឬខុស គ្នា?

ខ- ម៉ាសអាតូមធៀបសូដ្យូមគឺ 23,0 និងម៉ាសអាតូបធៀបម៉ាញេស្យូមគឺ 24,3) ។ ក្នុងចំណោមអាតូមទាំងពីរតើអាតូមណាមួយមានអ៊ីសូតូបតែមួយ? ចូរពន្យល់ ។

11. ស្ត្រុងចូម (Sr) មានលេខលំដាប់ 38 ។ វាជាធាតុមួយដែលស្ថិតនៅក្នុងខួបទី 5 និងក្រុមទី 2 នៃតារាងខួប ។ ចូរបំពេញនូវល្បះខាងក្រោមនេះ ដូច្នេះស្ត្រុងចូមមាន ÷

ក- .......................អេឡិចត្រុង ។

ខ- .........................ស្រទាប់អេឡិចត្រុង ។

គ- ..........................អេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់ ។

12. ខាងក្រោមនេះបង្ហាញពីការតម្រៀបអេឡិចត្រុងរបស់អាតូមមួយ ÷



ក- ចូរសរសេរគ្រោងអេឡិចត្រុងរបស់អាតូម ។

ខ- តើអាតូមនេះស្ថិតនៅក្នុងក្រុមណាមួយនៃតារាងខួប ហើយក្រុមនោះមានឈ្មោះអ្វី?

គ- ចូរឱ្យឈ្មោះធាតុមួយផ្សេងទៀតដែលមានចំនួនអេឡិចត្រុងនៅស្រទាប់ក្រៅដូចគ្នា ។